ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ១០១៥/ប.ស.ស
១៧


# សេចក្តីជូនដំណឹង

**បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)** សូមជម្រាប នាយកឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ជ្រាបថា ក្នុងការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ផ្នែកថែទាំសុខភាពកន្លងមក ប.ស.ស.សង្កេតឃើញមានកម្មករនិយោជិតមួយចំនួន បានប្រើប្រាស់ឯកសារវេជ្ជសាស្ត្រ (លិខិតចេញពីមន្ទីរពេទ្យ ឬ លិខិតបញ្ជាក់ពីគ្រូពេទ្យ ឬ វេជ្ជបញ្ជា) ដែលមានលក្ខណៈមិនប្រក្រតី (កោស លុប សរសេរបន្ថែមជាដើម) សម្រាប់ជាឯកសារយោងក្នុងការសុំអនុញ្ញាតច្បាប់ឈប់សម្រាកពីសហគ្រាស គ្រឹះស្ថាន ឬ ការទាមទារតាវកាលិកថែទាំសុខភាពពី ប.ស.ស។ ដើម្បីឲ្យឯកសារវេជ្ជសាស្ត្រខាងលើមានភាពត្រឹមត្រូវជាលិខិតយុត្តិការ ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម៖

១. ចំពោះករណីពិគ្រោះជំងឺក្រៅ (OPD): អ្នកជំងឺដែលជាកម្មករនិយោជិត (សមាជិក ប.ស.ស) ត្រូវមានឯកសារភស្តុតាង សម្រាប់ផ្តល់ជូននិយោជក ដែលបញ្ជាក់ថាខ្លួនពិតជាបានទៅពិគ្រោះជំងឺនៅមូលដ្ឋានសុខាភិបាល ដែលមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដូចជា វេជ្ជបញ្ជារបស់គ្រូពេទ្យ ឬសៀវភៅសុខភាព ឬលិខិតបញ្ជាក់សុខភាព ដែលឯកសារទាំងនេះ មិនត្រូវបានកោស ឬ លុប ឬសរសេរបន្ថែម និងត្រូវមានបោះត្រាជ្រុងដាក់ថា"ប.ស.ស" ឬមានការបញ្ជាក់ពីភ្នាក់ងារ ប.ស.ស ប្រចាំមូលដ្ឋានសុខាភិបាល។

២. ចំពោះករណីសម្រាកពេទ្យ (IPD): អ្នកជំងឺត្រូវមាន "លិខិតចេញពីមន្ទីរពេទ្យ" សម្រាប់ផ្តល់ជូននិយោជក ដែលបញ្ជាក់ថាខ្លួនពិតជាបានទៅសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាល ដែលមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដែលលិខិតនេះមិនត្រូវបានកោស ឬ លុប ឬសរសេរបន្ថែម និងត្រូវមានបោះត្រាជ្រុងដាក់ថា "ប.ស.ស" នៅលើលិខិតនោះ។

ប.ស.ស មិនទទួលស្គាល់ ចំពោះរាល់ឯកសារវេជ្ជសាស្ត្រ ដែលមានកិនភាគ ស្នាកស្នាមមិនប្រក្រតី ដូចបានបញ្ជាក់ខាងលើ សម្រាប់ជាឯកសារយោងនៃការទូទាត់ប្រាក់បំណាច់ប្រចាំថ្ងៃ ឬការទាមទារតាវកាលិកសង្គ្រោះបន្ទាន់ ឬអត្ថប្រយោជន៍ពាក់ព័ន្ធផ្សេងទៀតនោះឡើយ។

ប.ស.ស. សង្ឃឹមយ៉ាងមុតមាំថា និយោជក និងកម្មករនិយោជិត ដែលជាសមាជិក ប.ស.ស ទាំងអស់មានការយោគយល់ និងអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកញ្ញាឆ្នាំ២០១៧


អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៨ , ០២៣ ៨៨ ១០ ១៥ ០២៣-៨៨ ១០ ១៦ , ០២៣ ៨៨ ០៤ ១៧

ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O Box 70

Website : www.nssf.gov.kh